**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
សាលក្រមព្រហ្មទណ្ឌលេខ ១៨៣ គ
ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការសាធារណៈនៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្ដាល នាថ្ងៃ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧០ អ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរយោធា កន្លែងកំណើតសង្កាត់លេខ៣ ក្រុងភ្នំពេញ និងទីលំនៅបច្ចុប្បន្នភូ[redacted] ស្រុកកៀ ស្វាយ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (ស្លាប់) ជានីតិ ប្រពន្ធឈ្មោះ [redacted] (រស់) ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **លួចលក់អចលនវត្ថុរបស់អ្នកដទៃ** ប្រព្រឹត្តនៅ[redacted] ឃុំបន្ទាយដែក ស្រ កៀន ស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា២៥៨ នៃច្បាប់ភូមិបា

- មានលោក [redacted] សូតា ជាមេធាវីការពារសិទ្ធិ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មុខរប រាជការ ទីលំនៅ[redacted]ណ្ឌមានជ័យ រាជធានីភ្នំពេញ។

- មានលោកស្រី [redacted] សុផល ជាមេធាវីការពារសិទ្ធិ ។

**រីឯរឿងហេតុមានដូចតទៅ ៖**

ដើមបណ្ដឹងឈ្មោះ [redacted] ជូរហុង បានគ្រប់គ្រង អាស្រ័យផលនៅលើដីទំហំ៦៨ហិចតា រួមទាំ ផ្សេងទៀតដែលខ្លួនបានប្រមូលទិញដោយស្របច្បាប់ពីប្រជាពលរដ្ឋ[redacted] ឃុំបន្ទាយដែក ប្រ



Scanned with CamScanner

គៀនស្វាយ ខេត្តកណ្ដាល ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះហត្ថលេខាទទួលស្គាល់នៅអាជ្ញា
ដែនដី ភូមិឃុំដែលគ្រប់គ្រង នៅមូលដ្ឋានផ្ទាល់ ហើយដែលខ្លួនបានគ្រប់គ្រងរហូតមិនដែលអាកខា
ចាប់តាំងពីឆ្នាំ២០១០-២០១២ រហូតដល់បច្ចុប្បន្ននេះមិនដែលអាក់ខានឡើយ។

ស្រាប់តែនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានឃើញឈ្មោះ [redacted] សុវណ្ណ ទៅបញ្ជាឲ្យ
ដឹកបង្គោលថ្មយកទៅដឹកកប់នៅលើដីរបស់ខ្លួន ដោយព័ទ្ធចូលក្នុងដីខ្លួនទំហំ៦៨ហិចតា ពេលនោះខ្លួ
និងប្រជាពលរដ្ឋនៅទីនោះចំនួន ០២នាក់ទៀត មានឈ្មោះ [redacted] ឆាង និងឈ្មោះ [redacted] ថា បានឃ
មិនឲ្យបោះបង្គោលនៅលើដីរបស់ខ្លួន ព្រោះដីខ្លួនមានប្រឡាយព័ទ្ធជុំវិញ ហើយខ្លួនកាន់កាប់ជាយូរ
ហើយ ពេលនោះលោក [redacted] សុវណ្ណ បានស្រែកឡូឡាប្រមាថដល់អាយុជីវិតរបស់ឈ្មោះ [redacted] ឆ
ហើយលោក [redacted] **ម៉េងឡុង** ដែលជាអ្នកទិញដីរបស់ខ្លួនពីឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា គាត់ទិញ
នេះពីលោក [redacted] សុវណ្ណ នៅចុងឆ្នាំ២០១៧ ហើយកាលនោះទឹកលិច ជិះទូកមកមើលមិនបានឃើញ
ទេឃើញតែទឹក ដោយលោក [redacted] សុវណ្ណ អះអាងថាដីនេះជាដីរបស់ភូមិភាគ ហើយបានលក់ឲ្យ ត
[redacted] **ឡុង** ទំហំ១២៥ហិចតា ក្នុងមួយហិចតា តម្លៃតែ២.៥០០$ ប៉ុណ្ណោះ ដោយធ្វើលិខិតផ្ទេរសិទ្ធិក
កាប់ដីចុះហត្ថលេខាដល់អាជ្ញាធរស្រុក ហើយឲ្យគាត់បង់ប្រាក់ចំនួន ៩០% ខែកុម្ភៈ ឆ្នាំ២០១៨ រ
សន្យាចុះបោះបង្គោលព្រំ ហើយបង់ប្រាក់បន្ថែម ១០%បង្គ្រប់១០០% ប៉ុន្តែចេះតែមានការពន្យារប
ដល់ខែឧសភា ឆ្នាំ២០១៨ នេះ ពេលបុណ្យចម្រើនព្រះជន្មទើបបានចុះបោះបង្គោល ហើយលោក ត
[redacted] ឡុង ក៏បានបញ្ជាក់ដែរថាពេលចុះមកបោះបង្គោលលើដីនេះ ដែលជាពេលទឹកគោក ទើបគ
មើលឃើញច្បាស់ថាដីនេះពិតជាដីរបស់ខ្លួន [redacted] **ជួរហុង** និងដីរបស់លោក [redacted] ម៉េង ទេ តែឈ្មោះ
[redacted] ណ្ណ នៅតែអះអាងថាដីនេះមិនមែនជាដីរបស់ខ្លួន តាន់ជួរហុង និងឈ្មោះ [redacted] ម៉េង ទេ នៅតែថាដ
របស់ភូមិភាគ ដែលតាមការពិតនរណាក៏គេដឹងច្បាស់ថាដីរបស់ភូមិភាគគឺស្ថិតនៅចំងាយពីដីរបស់
នេះ ៤០០ម៉ែត្រទៅ ៥០០ម៉ែត្រឯណោះ។

លោក [redacted] **ម៉េងឡុង** បានប្រាប់ខ្លួនថាដីនេះគាត់ទិញចុងឆ្នាំ២០១៧ តែអាជ្ញាធរបានហៅ
ឲ្យចុះហត្ថលេខា ដោយចុះថ្ងៃខែ ដាក់ឆ្នាំ២០១៦ ហើយគាត់បានណាត់ខ្លួន [redacted] ជួរហុង ,លោក លី
ង នឹងឈ្មោះ [redacted] ផាន់ណា មកជួបជុំគ្នាពិនិត្យឯកសារនៅផ្សារ TK ជិតរង្វង់មូលទួលគោកដើម្បី
ទារប្រាក់ពីឈ្មោះ [redacted] សុវណ្ណ វិញ។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ ខ្លួននិងឈ្មោះ [redacted] ម៉េងឡុង ,ឈ្មោះ [redacted] ម៉េង និងលេ
[redacted] ផាន់ណា ក៏បានមកជួបគ្នា ហើយបាននិយាយពីការហួសចិត្តដែលលោក [redacted] សុវណ្ណ លួចល
របស់ខ្លួន និងដីរបស់លោក [redacted] ម៉េង នេះ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៥២៨ ដកសព ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ រ
តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល។

**បានឃើញ** ដីកាដំណោះស្រាយលេខ ៦៦២ ដកជស ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៧១៣ ដកចត ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

-**បានឃើញ** ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ១៧១ ដកសជជរ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមជំនុំជម្រះ។

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា កាលពីឆ្នាំ១៩៩៨ ខ្លួនជាប្រធានបញ្ញាការផ្នែកកសិកម្ម ស្រុកកៀនស្វាយ បានសុំគោលការណ៍មេបញ្ញាការយោធភូមិភាគពិសេស ដើម្បីស្នើសុំអាជ្ញាធរមូលដ្ឋានកាន់កាប់ដីទំហំ ៥០០ ហិកតា ស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដើម្បីធ្វើកសិផលទ្រទ្រង់អង្គភាព ដែលមានអភិបាលស្រុក ប្រធានការិយាល័យកសិរុក្ខាប្រមាញ់និងនេសាទ ស្រុកកៀនស្វាយ និងមេឃុំទទួលស្គាល់ដឹងឮ។ ចាប់ពីឆ្នាំ១៩៩៨ រហូតដល់បច្ចុប្បន្ននេះ អង្គភាពរបស់ខ្លួនបានឈរជើងនិងកានកាប់លើដីខាងលើនេះ។ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ខ្លួនពិតជាបានលក់ដីទំហំ ១២៥ ហិកតា ស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឲ្យទៅឈ្មោះ [redacted] ម៉េងឡុង ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ដីធ្លីលេខ ៦១៥ សកល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានអាជ្ញាធរឃុំ និងស្រុកដឹងឮ។ ការលក់ដីខាងលើនេះ គឺដើម្បីដោះស្រាយជីវភាពរបស់អង្គភាពហើយមុនពេលលក់ ខ្លួនសុំគោលការណ៍ពីថ្នាក់លើដើម្បីចាត់ចែងដីខាងលើជាមួយអាជ្ញាធរ។ ក្នុងឆ្នាំ២០១០ ឈ្មោះ [redacted] ជួរហុង បានទិញដីពីប្រជាពលរដ្ឋ នៅក្នុងដីរបស់អង្គភាពខ្លួន តែខ្លួនពុំដឹងនោះទេ។ ស្រាប់តែក្នុងឆ្នាំ២០១៨ ខ្លួនអ្នកទិញបានចុះបោះបង្គោលដីក៏មានឈ្មោះ [redacted] ជួរហុង អះអាងជាដីស្ថិតនៅក្នុងភូមិខ្លួន។

តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] ជួរហុង បានឆ្លើយថា ខ្លួនបានស្គាល់ឈ្មោះ [redacted] សុវណ្ណ តាមរយៈមិត្តភ័ក្ដ ហើយឈ្មោះ [redacted] សុវណ្ណ ធ្លាប់កាយព្រំដីឲ្យមិត្តភ័ក្ដរបស់ខ្លួនដែរ។ កាលពីឆ្នាំ២០១០ ខ្លួនទិញដីស្រែប្រាំងចំនួន ៦៨ហិកតា ពីប្រជាពលរដ្ឋចំនួន ១៩គ្រួសារ ស្ថិតនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដែលមានធ្វើលិខិតផ្ទេរសិទ្ធិគ្រប់គ្រងដីធ្លី និងប្រើប្រាស់ដីធ្លីដោយមានអាជ្ញាធរភូមិឃុំចុះហត្ថលេខាដឹងឮ និងបានវាស់វែងត្រឹមត្រូវ។ បន្ទាប់ពីការទិញដីប្រជាពលរដ្ឋក្នុងអំឡុងឆ្នាំ២០១០ ខ្លួនបានកាន់កាប់និងបង្កបង្កើនផលលើដីនេះរហូតដល់បច្ចុប្បន្ន។ ក្នុងឆ្នាំ២០១៤ អាជ្ញាធរថ្នាក់ខេត្តបានចុះអង្កេតវាស់វែងដីក្នុងតំបន់កៀនស្វាយ ដើម្បីធ្វើបច្ចុប្បន្នភាព ហើយខ្លួនក៏បានចូលរួមវាស់វែងជាមួយអាជ្ញាធរក្នុងនាមជាម្ចាស់កម្មសិទ្ធិ។ ចុងឆ្នាំ២០១៧ អំឡុងខែធ្នូ ក៏ឃើញមានឈ្មោះ [redacted] ម៉េងឡុង ភេទប្រុស អាយុ៣៦ឆ្នាំ មានទីលំនៅផ្ទះលេខ២ ផ្លូវ៥៩២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ៥៨ឆ្នាំ បានជិះ



Scanned with CamScanner

ទៅមើលដី ប៉ុន្តែខ្លួនពុំចាប់អារម្មណ៍ថា ទិញពីអ្នកណានោះទេ។ ស្រាប់តែក្នុងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៨ មានឈ្មោះ [redacted] ឆាយ ភេទប្រុស អាយុ៥៦ឆ្នាំ រស់នៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល បានទូរស័ព្ទមកប្រាប់ខ្លួនថា មានឈ្មោះ [redacted] សុវណ្ណ បានមកបោះបង្គោលលើដីរបស់ខ្លួនចំនួន ៦៨ហិកតា។ ហើយនៅថ្ងៃទី១៦ ខែឆ្នាំដដែលខ្លួនក៏បានចុះទៅមើលទីតាំងដី ឃើញមានការបោះបង្គោលពិតមែន។ លុះថ្ងៃទី១៨ ខែឆ្នាំដដែល ខ្លួនក៏ចុះទៅមើលទីតាំងដីម្តងទៀត បានជួបនឹងឈ្មោះ [redacted] ម៉េងឡុង (ជាអ្នកទិញដីពីឈ្មោះ [redacted] សុវណ្ណ) ហើយក៏បានបង្ហាញលិខិត សិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៦១៥ សកល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលឈ្មោះ គឹម សុវណ្ណ ផ្ទេរសិទ្ធិឲ្យឈ្មោះ [redacted] ម៉េងឡុង ថែមទាំងប្រាប់មកខ្លួនថាគាត់ទិញដីពីឈ្មោះ គឹម សុវណ្ណ ចុងឆ្នាំ២០១៧ ប៉ុន្តែធ្វើលិខិតផ្ទេរសិទ្ធិក្នុងឆ្នាំ២០១៦ គឺឈ្មោះ [redacted] សុវណ្ណ ជាអ្នកដាក់ខែឆ្នាំខ្លួន ហើយគាត់បានបន្ថែមទៀតថា គាត់ទិញដីពីឈ្មោះ [redacted] សុវណ្ណ ក្នុង០១ហិកតា តម្លៃ២.៥០០ដុ បន្ទាប់មកឈ្មោះ [redacted] ម៉េងឡុង ក៏បានណាត់ជួបខ្លួននៅផ្សារ TK ទួលគោក រាជធានីភ្នំពេញ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨ ដើម្បីជួបនិយាយគ្នារឿងទិញដីជាន់ដីខ្លួន ខណៈនោះឈ្មោះ [redacted] ម៉េងឡុង បានទូរស័ព្ទហៅឈ្មោះ [redacted] សុវណ្ណ ពេលដែលឈ្មោះ [redacted] សុវណ្ណ មកដល់ប្រកែកថាជាដីភូមិភាគ មិនមែនជាដីខ្លួនទេ ក៏មានការឈ្លោះប្រកែកគ្នាទៅ។ លុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ខ្លួនក៏បាន ឈ្មោះ [redacted] **ម៉េងឡុង** ជាមួយឈ្មោះ [redacted] **ម៉េង** ,ឈ្មោះ [redacted] **ផាន់ណា** នៅផ្សារ TK ទួលគោក រាជធានីភ្នំពេញ ហើយឈ្មោះ សុខ ម៉េងឡុង បាននិយាយថានឹងយកលុយកកពីឈ្មោះ [redacted] **សុវណ្ណ** វិញហើយ ឈ្មោះ [redacted] **ម៉េងឡុង** ក៏ទទួលស្គាល់ជាដីកម្មសិទ្ធិរបស់ខ្លួនដែរ។ ក្រោយមកទើបខ្លួនដាក់ពាក្យបណ្តឹង មកកាន់អយ្យការអមសាលាដំបូងខេត្តកណ្តាលតែម្តង។ ខ្លួនពុំដែលពាក់ព័ន្ធឲ្យឈ្មោះ [redacted] សុវណ្ណ ព ដីឲ្យខ្លួននោះទេ។

តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **ឆាង** បានឆ្លើយថាខ្លួនគឺជាអ្នកចាំដីឲ្យឈ្មោះ [redacted] ជួរហ ហើយដីនេះមានទីតាំងស្ថិតនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលដីនេះ ឈ្មោះ [redacted] ជួរហុង ទិញពីប្រជាជនតាំងពីឆ្នាំ២០១០ បន្ទាប់ពីទិញឈ្មោះ [redacted] ជួរហុង បានកាន់កាប់ និងបង្កបង្កើតផលរហូតមកទល់បច្ចុប្បន្ន។ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ ខ្លួនចុះទៅមើលទីតាំង របស់ឈ្មោះ [redacted] ជួរហុង ស្រាប់តែឃើញមានកម្មករកំពុងបោះបង្គោលព្រំដី ពេលនោះខ្លួនក៏សួរកម្មករ នោះ ពួកគាត់ប្រាប់ថាលោក [redacted] សុវណ្ណ ឲ្យបោះរួចខ្លួនក៏ត្រឡប់មកផ្ទះវិញ ហើយថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានទូរស័ព្ទទៅឈ្មោះ [redacted] ជួរហុង ប្រាប់ថាដីបងឯងត្រូវគេលួចលក់ហើយ គាត់ក៏ ថា អ្នកណា ខ្លួនប្រាប់ថាឈ្មោះ [redacted] **សុវណ្ណ** ប្រធានឃោធាស្រុកកៀនស្វាយ។ បន្ទាប់មកនៅថ្ងៃទី ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ [redacted] ជួរហុង បានចុះមកមើលដីរបស់គាត់ក៏ឃើញបង្គោលលើដីរបស់ គាត់មែន តែពុំជួបអ្នកណាទេ។ លុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ [redacted] ជួរហុង ក៏ចុះមក



Scanned with CamScanner

ម្តងទៀតក៏ជួបជាមួយឈ្មោះ [redacted] ម៉េងឡុង (ជាអ្នកទិញដីពីឈ្មោះ [redacted] សុវណ្ណ) ពេលនោះឈ្មោះ [redacted] ជួរហុង ក៏បានសួរទៅឈ្មោះ [redacted] ម៉េងឡុង ថាហេតុអីបានជាមកបោះបង្គោលលើដីខ្ញុំ ឈ្មោះ [redacted] ម៉េងឡុង ក៏តបវិញថាដីនេះខ្ញុំទិញពីឈ្មោះ [redacted] សុវណ្ណ ក្នុងខែធ្នូ ឆ្នាំ២០១៧ ពេលនោះឈ្មោះ [redacted] ម៉េងឡុង ក៏បានទូរស័ព្ទហៅឈ្មោះ [redacted] សុវណ្ណ។ បន្ទាប់មកឈ្មោះ [redacted] សុវណ្ណ បានមកជាប់ តាំងដីហើយឈ្មោះ [redacted] ជួរហុង បានសួរទៅឈ្មោះ [redacted] សុវណ្ណ ថាហេតុអីបានលក់ដីខ្ញុំ ឈ្មោះ [redacted] សុវណ្ណ តបមកវិញថាជាដីរបស់ភូមិភាគទេ ខណៈនោះខ្លួនបានឆ្លើយវិញថា មិនមែនជាដីភូមិភាគ កន្លែងនេះទេ ដីភូមិភាគនៅត្បូងក្តុលបីដើម ឈ្មោះ [redacted] សុវណ្ណ បាននិយាយថាខ្ញុំស្គាល់ដីភូមិភាគ ច្បាស់ណាស់ ខ្លួនក៏និយាយវិញថាលោកឯងច្រឡំ។ ឈ្មោះ [redacted] សុវណ្ណ បាននិយាយថា មកពីប៉ុ ខ្លាំងទើបឆ្នាំ២០០៥ អញ់បាញ់ផ្ទះហ្អែង រំពេចនោះខ្លួនបាននិយាយថាអញកំពុងរកមុខបើហ្អែងខ្ល បាញ់ទៀតមក បន្ទាប់មកឈ្មោះ [redacted] ជួរហុង ក៏ទាញខ្លួនឡើងលើម៉ូតូ ហើយខ្លួនក៏ជិះម៉ូតូត្រឡប់ ផ្ទះវិញ។ ក្រោយមកឈ្មោះ [redacted] ម៉េងឡុង បានទូរស័ព្ទមកខ្លួនឲ្យប្រាប់ឈ្មោះ [redacted] ជួរហុង និងលេ [redacted] ម៉េង ណាត់ជួបថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ នៅផ្សារ TK ទួលគោក រាជធានីភ្នំពេញ ដើម្បីពិនិ ឯកសារដី។ ពេលដែលជួបនៅផ្សារ TK ទួលគោក រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០ លោក [redacted] ម៉េងឡុង បាននិយាយថា ដីបងឯងនៅតែជាដីបងឯង ពេលដែលខ្លួនវិលទៅវិញនឹង លុយលោក [redacted] សុវណ្ណ វិញ។

មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា នៅក្នុងរឿងនេះគឺកូនក្តីរបស់នា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដីដែលជនជាប់ចោទបានលក់ទៅឲ្យឈ្មោះ [redacted] ម៉េងឡុង គឺ របស់កូនក្តីនាងខ្ញុំពិតប្រាកដមែន ហើយទោះបីជាជនជាប់ចោទបានខិតខំអះអាងថាជារបស់ខ្លួន ណាក៏ដោយ ប៉ុន្តែជនជាប់ចោទគ្មានភស្តុតាងណាមួយមកធ្វើជាសំអាងនោះដែរ ហើយជាលទ្ធផ គណៈកម្មការដោះស្រាយដីធ្លីថ្នាក់ស្រុកបានបដិសេធការតវ៉ារបស់ជនជាប់ចោទទាំងស្រុង ចំណែ អ្នកទិញឈ្មោះ [redacted] ម៉េងឡុង ក៏មានការសោកស្តាយដែលបានទិញដីដែលមានការពាក់ព័ន្ធជ ដែរ។ ករណីនេះបានធ្វើឲ្យកូនក្តីនាងខ្ញុំបាត់បង់ដីអស់ ៦៨ហិចតា។ សំណូមពរផ្តន្ទាទោសជន ចោទទៅតាមច្បាប់ និងទាមទារសំណងចំនួន៥០០.០០០.០០០រៀល។

**តំណាងអយ្យការធ្វើការសន្និដ្ឋានថា** បន្ទាប់ពីពិភាក្សាដេញដោលរួចមកឃើញថា ជនជ ចោទពិតជាបានលក់ដីរបស់ដើមបណ្តឹងអស់ចំនួន ៦៨ហិចតាពិតប្រាកដមែន តំណាងអយ្យការសុំរ ការចោទប្រកាន់លើជនជាប់ចោទដដែល ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ លេខ ៥២៨ ដ សព ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ និងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសតាមច្បាប់។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទថា ដីដែលកូនក្តីរបស់ខ្ញុំបានលក់គឺជាដីរបស់គា ដោយគាត់មានឯកសារបញ្ជាក់ត្រឹមត្រូវ ក៏ប៉ុន្តែដើម្បីមានមូលដ្ឋានច្បាស់លាស់ ខ្ញុំសុំតុលាការចា របៀប ដើម្បីស៊ើបសួរពីឯកសារទិញ លក់ដីរបស់ភាគីដើមបណ្តឹង ពិសេសឈ្មោះអ្នកទិញ។

## សាលាដំបូងខេត្តកណ្តាល

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

## សំអាងហេតុ

១/. រឿងក្តីកើតឡើងដោយសារតែនៅពេលដែលដើមបណ្តឹងចាប់ផ្តើមសុំធ្វើការចុះបញ្ជីដីធ្លីរ ស្ថាប័នជំនាញ ស្រាប់តែជនជាប់ចោទបានចេញមកដាក់បណ្តឹងជំទាស់ថា ដីដែលដើមបណ្តឹងសុំ បញ្ជីនោះ មួយចំនួនប៉ះលើដីរបស់ខ្លួន។ ស្ថាប័នជំនាញដីធ្លីថ្នាក់ស្រុកចាប់ផ្តើមធ្វើការអង្កេតស្រាវជ្រ ចប់សព្វគ្រប់ បានរកឃើញថា ជនជាប់ចោទគ្មានឯកសារភស្តុតាងច្បាស់លាស់បញ្ជាក់ពីសិទ្ធិរបស់ លើដីដែលខ្លួនបានជំទាស់នោះទេ ហើយសាក្សីមួយចំនួនដែលមានឈ្មោះនៅលើឯកសារដីរបស់ ជាប់ចោទដូចជាមេភូមិ មេឃុំ បានធ្វើការបដិសេធ និងបញ្ជាក់ពីការកសាងឯកសារមិនបានត្រឹម តាមជាក់ស្តែង ផ្ទុយទៅវិញគឺជនជាប់ចោទទៅវិញទេ ដែលបានលក់ដីរបស់ដើមបណ្តឹងអស់ចំ ៦៨ហិចតា អោយទៅឈ្មោះ [redacted] ម៉េងឡុង។ ហើយជំនាញដីធ្លីថ្នាក់ស្រុកបានបដិសេធនូវបណ្តឹ ជំទាស់របស់ជនជាប់ចោទចោលទាំងស្រុង។

២/. តាមភស្តុតាងជាលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០ បញ្ជាក់ថា ជនជាប់ចោទពិតជាបានលក់ដី ដោយទាំងដីរបស់ដើមបណ្តឹងអស់ចំនួន ៦៨ហិចតា ប្រាកដមែន។

៣/. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ៥ ជនជាតិខ្មែរ ពីបទ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិខ្សាំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិប និងត្រូវប្រកាសទោសតាមមាត្រា ៣៥០ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៨/ ដើមបណ្ដឹងរដ្ឋប្បវេណី ទាមទារសំណងការខូចខាតចំនួន៥០០ ០០០ ០០០រៀល តុលាការពិចារណាតាមមាត្រា២ , មាត្រា១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី**

១/. ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ ដា ពន្ធនាគារចំនួន ០១(មួយ)ឆ្នាំ ពីបទ *លួចលក់អចលនវត្ថុរបស់អ្នកដទៃ* ប្រព្រឹត្តនៅ [redacted] ឃុំបន្ទា ដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បា ភូមិបាល។

២/. ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] សុវណ្ណ ។ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រ ទណ្ឌ។

៣/. បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ សងសំណងជម្ងឺចិត្តចំនួន ៥០.០០០.០ (ហាសិបលាន)រៀល។

-ច្រានចោលការទាមទារលើសពីនេះ របស់ដើមបណ្ដឹងរដ្ឋប្បវេណី។

៤/.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខជនជ ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ កំបាំង ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា [redacted] | ហត្ថលេខា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ...... ខែ...... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កណ្ដាល,ថ្ងៃទី...... ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner